**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** :...............០៣២/១៨............**ក.ប**/ស.ជ.ណ.អ.ធ.ក

# <u>សេចក្តីជូនដំណឹង</u>

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបដល់ម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថានទាំងអស់ដែលស្ថិតក្នុងដែនអនុវត្តនៃច្បាប់ស្តីពីការងារឱ្យបានជ្រាបថា យោងតាមច្បាប់ស្តីពីការងារ និងប្រកាសរបស់ក្រសួងលេខ៤៩៣ ក.ប/ប្រ.ក.អ.ធ.ក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការឈប់បុណ្យដែលត្រូវមានប្រាក់ឈ្នួលប្រចាំឆ្នាំ២០១៨ និងដើម្បីបង្កលក្ខណៈងាយស្រួលដល់បងប្អូនកម្មករនិយោជិតក្នុងឱកាសបុណ្យភ្ជុំបិណ្ឌខាងមុខនេះ សូមម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថានទាំងអស់អនុវត្តដូចតទៅ៖

១- អនុញ្ញាតឱ្យកម្មករនិយោជិតទាំងអស់របស់ខ្លួនឈប់សម្រាកដោយមានប្រាក់ឈ្នួលនាឱកាសបុណ្យភ្ជុំបិណ្ឌខាងមុខនេះ ក្នុងកំឡុងពេលបីថ្ងៃគឺ **ថ្ងៃទី៨-៩ និង ១០ ខែតុលា ឆ្នាំ២០១៨** ។

២- ខិតខំរៀបចំបើកប្រាក់ឈ្នួលកម្មករនិយោជិតឱ្យបានមុនថ្ងៃបុណ្យភ្ជុំបិណ្ឌ។បើពុំមានលទ្ធភាពបើកប្រាក់ឈ្នួលទាន់ពេលទេសូមអនុញ្ញាតឱ្យកម្មករនិយោជិតទទួលប្រាក់បុរេប្រទានយ៉ាងតិច៥០% (ហាសិបភាគរយ) មុនពេលបុណ្យភ្ជុំបិណ្ឌ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា លោក លោកស្រី ជាម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថានទាំងអស់នឹងអនុវត្តឱ្យបានត្រឹមត្រូវតាមសេចក្តីជូនដំណឹងនេះប្រកបដោយប្រសិទ្ធភាព។

ថ្ងៃ ព្រហស្បតិ៍ ៤រោច ខែ ស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៨

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**<u>ចម្លងជូន ៖</u>**

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យ**សម្តេចតេជោនាយករដ្ឋមន្ត្រី**

-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី

-ក្រសួងព្រះបរមរាជវាំង

-គ្រប់ក្រសួងពាក់ព័ន្ធ

"ដើម្បីជូនជ្រាប "

-គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី-ខេត្ត

"ដើម្បីផ្សព្វផ្សាយ នឹងអនុវត្ត "

-សមាគមនិយោជក

-សហព័ន្ធសហជីព កម្មករនិយោជិត

"ដើម្បីជ្រាប និងអនុវត្ត "

-កាលប្បវត្តិ និងឯកសារ

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩